STREAM

NACA

# អត្ថបទយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា



ខែធ្នូ ឆ្នាំ ២០០២

# I.អារម្ភកថា

**តើ STREAM ជាអ្វី ?**

STREAM (គំរោងជួយគ្រប់គ្រងធនធានវារីជាតក្នុងតំបន់ ) ជាគំរោងរៀនសូត្រ និង ទំនាក់ទំនងក្នុងតំបន់មួយដែលត្រូវបានផ្តល់អាណត្តិដោយរដ្ឋាភិបាលនៅតំបន់អាស៊ីប៉ាស៊ីភិចចំនួន ១៥ ហើយគ្រោងឡើងក្នុងរយៈពេល៥ឆ្នាំនៃកម្មវិធីការងារ របស់ NACA (បណ្តាញនៃមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច)។ ទិសដៅរបស់គំរោងគឺ ដើម្បីពង្រឹង ឬ អភិវឌ្ឍន៍ និង ទំនាក់ទំនងយុទ្ធសាស្រ្ត ដំណើរការ និង ការអនុវត្តន៍ដែលអាចឱ្យអ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះនៅតំបន់អាស៊ីប៉ាស៊ីភិចទទួលបាននូវទិសដៅចិញ្ចឹមជីវិតរបស់ខ្លួន។ យើងធ្វើការជាមួយដៃគូរដើម្បីធានា:

១. អ្នកផ្តល់សេវាកម្ម មានការយល់ដឹងពី**ការចិញ្ចឹមជីវិត**របស់អ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះ

២. **ស្ថាប័ន**ជួយដល់ទិសដៅចិញ្ចឹមជីវិតរបស់អ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះកាន់តែប្រសើរ

៣.ដំណើរការអភិវឌ្ឍន៍**គោលនយោបាយ**ឆ្លើយតបទៅនឹងទិសដៅចិញ្ចឹមជីវិតរបស់អ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះ

៤. ការទំនាក់ទំនងក្នុងចំណោមអ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះ អ្នកផ្តល់សេវាកម្ម ស្ថាប័ន និង អ្នកធ្វើគោលនយោបាយត្រូវបានលើកកំពស់

គំរោង STREAM គឺផ្អែកលើភាពជាដៃគូរជាច្រើន ដែលក្នុងនោះនៅពេលចាប់ផ្តើមមានដៃគូរ (DFID, VSO, FAO) ជួយដល់ (NACA, STREAM) ហើយបច្ចុប្បន្ន STREAM មានការជួយឧបត្ថម្ភពី AusAID, APEC និង DFID NRSP ។ STREAM គំរោងនឹងទទួលយកនូវយុទ្ធវិធីសមស្របមួយដើម្បីសំរេចឱ្យបាននូវ ទំនាក់ទំនងរវាង អ្នកពាក់ព័ន្ធទាំងអស់ដែលជាប់ទាក់ទិននឹងការគ្រប់គ្រងធនធានជលផល និងជួយពួកគេឱ្យរួមចំណែកក្នុងការរៀបចំ, អនុវត្តន៍ និងការគ្រប់គ្រងគំរោង ។ ការងាររបស់ STREAM ត្រូវបានសំរបសំរួលនៅប្រទេសនិមួយៗតាមរយៈ ការិយាល័យតាមប្រទេសរបស់ STREAM ដែលក្រុមនេះរួមមាន អ្នកសំរបសំរួលជាតិម្នាក់ (គឺជាមន្រ្តីជាន់ខ្ពស់ម្នាក់ដែលមានការយល់ព្រមជាមួយរដ្ឋាភិបាល) និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង (ជាមន្រ្តីធ្វើការពេញម៉ោងដែលជួយឧបត្ថម្ភដោយ STREAM នៅក្នុងរយៈពេលពីឆ្នាំដំបូង) ដោយភ្ជាប់ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ព័ន្ធថ្នាក់ជាតិទាំងអស់។ ក្រុមនេះត្រូវបានគេផ្តល់ឱ្យនូវ សំភារៈឧបករណ៏ បច្ចេកវិទ្យាពត៌មាន បណ្តាញ និង ការជួយឧបត្ថម្ភអភិវឌ្ឍន៏ធនធានមនុស្ស។ ការិយាល័យថ្នាក់ជាតិភ្ជាប់ទំនាក់ទំនងជាមួយការិយាល័យថ្នាក់តំបន់ តាមរយៈបណ្តាញអ៊ីនធឺណេតថ្នាក់តំបន់។ ការិយាល័យ STREAMថ្នាក់តំបន់ (នៅលេខាធិការដ្ឋាន NACA នៅទីក្រុងបាងកក)ធ្វើការដឹកនាំគំរោង ផ្តល់នូវការសំរបសំរួលថ្នាក់តំបន់ និង ជួយនូវអន្តរកម្ម សកម្មភាពផ្លាស់ប្តូរនូវបទពិសោធន៏ និង ភាពជាដៃគូរ។

## តើអត្ថបទយុទ្ធសាស្ត្ររបស់ប្រទេស (CSP)ជាអ្វី?

នៅក្នុងប្រទេសនិមួយៗដែល STREAMបានធ្វើការ អត្ថបទយុទ្ធសាស្ត្ររបស់ប្រទេស (CSP) ត្រូវបានរៀបចំដោយធ្វើការពិគ្រោះយោបល់ជាមួយអ្នកជាប់ពាក់ព័ន្ធនានា និង ដោយមានការជួយជ្រោមជ្រែងពីការិយាល័យថ្នាក់តំបន់នៅទីក្រុងបាងកក។ CSP រកមើលនូវបញ្ហាដែលទាក់ទងនឹងធនធានវារីជាត និង ភាពក្រីក្រ ដោយពិនិត្យមើលលើបរិស្ថានគោលនយោបាយ និង ស្ថាប័នការបង្កើតនូវគោលបំណងសំខាន់ៗ សំណើយុទ្ធសាស្ត្រអនុវត្ត ដោយសង្កត់ធ្ងន់លើភាពជាដៃគូរជាមួយអ្នកជាប់ពាក់ពន្ធ័ថ្នាក់ជាតិ និង តំបន់ និង ផ្តល់នូវមូលដ្ឋានដើម្បីស្វែងរកការជួយឧបត្ថម្ភថវិកា និង ធនធានពី STREAM ពីដៃគូររបស់ STREAM និង ប្រភពផ្សេងៗទៀត។

អត្ថបទយុទ្ធសាស្ត្ររបស់ប្រទេស (CSP) មានអាចសុពលភាពរហូតដល់ ៣ ទៅ៥ ឆ្នាំ។ CSP និងដំណើរការ និង ការអនុវត្តដើម្បីអភិវឌ្ឍន៏វា នឹងត្រូវបានសើរើ និង ផ្លាស់ប្តូរនៅពេលដែលស្ថានភាពផ្លាស់ប្តូរ និង មានបទពិសោធន៏ថ្មីៗ។ CSP នឹងធ្វើជាទំរង់ការណែនាំដែលអនុញ្ញាតឱ្យការិយាល័យ STREAM ថ្នាក់ជាតិ និង ថ្នាក់តំបន់អាចធ្វើផែនការសកម្មភាពកាន់តែលំអិត ដូច្នេះគំរោង STREAM អាចផ្តោតការខិតខំដើម្បីសំរេចនូវទិសដៅ និង លទ្ធផលរបស់ខ្លួន ជុំវិញគោលសំខាន់ៗ: ***ការចិញ្ចឹមជីវិត ស្ថាប័ន*** *គោលនយោបាយ និង ការទំនាក់ទំនង* ។

## II. សង្ខេប

កម្ពុជាគឺជាប្រទេសមួយដែលក្រីក្រជាងគេបង្អស់នៅលើពិភពលោក ភាគច្រើននៃប្រជាជនរស់នៅតំបន់ជនបទ និង រស់ក្រោមខ្សែបន្ទាត់ភាពក្រីក្រ។ ការគ្រប់គ្រងធនធានវារីជាតសាធារណៈគឺមានសារៈសំខាន់ដល់សុវត្ថិភាពស្បៀង និង ការអភិវឌ្ឍន៍ជនបទនៅ កម្ពុជាដោយនិរន្តរភាព។ ក្រុមមនុស្សក្រីក្រដែលប្រើប្រាស់ធនធានវារីជាតថាជាផ្នែកមួយនៃយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ខ្លួនគឺ អ្នកនេសាទគ្រួសារ វារីវប្បករទ្រង់ទ្រាយតូច និង អ្នកប្រមូលធនធានវារីជាត។ អ្នកនេសាទគ្រួសារគឺច្រើនធ្វើនៅតាមទន្លេ បឹង និង តំបន់ព្រៃលិចទឹកនៅតាមខេត្តជាប់នឹងបឹងទន្លេសាប តំបន់ទន្លេមេគង្គ និង ទន្លេបាសាក់ និង ផ្នែកខាងលើនៃទន្លេមេគង្គ។ វារីវប្បករទ្រង់ទ្រាយតូច និង/ឬ អ្នកប្រមូលធនធានវារីជាតគឺភាគច្រើននៅខេត្តដែលមិនសំបូរធនធានជលផលដែលរួមមាន ខេត្ត កំពង់ស្ពឺ រតនៈគីរី មណ្ឌលគីរី ព្រះវិហារ និង ខេត្តឧត្តរមានជ័យ។ ផលនេសាទទឹកសាបបានរួមចំណែកយ៉ាងសំខាន់ដល់សុវត្ថិភាព ស្បៀង និង សេដ្ឋកិច្ចជាតិកម្ពុជា ច្រើនជាងបណ្តាប្រទេសនានានៅលើពិភពលោក។

ការធ្វើឯកជនភាវូបនីយកម្មនៃជលផលទឹកសាបជាតិ (ឡូតិ៍នេសាទ) បានធ្វើឱ្យអ្នកនេសាទគ្រួសារមានជំលោះជាមួយថៅកែឡូតិ៍ដែល ទោះបីជាមានច្បាប់ក៏ដោយក៏ពួកគេមិនឱ្យអ្នកនេសាទគ្រួសារចូលនេសាទតាមរយៈ ការគំរាមកំហែង ប្រើអំពើហិង្សា និង សម្លុតដាក់គុក។ ការរំជើបរំជួលនៅក្នុងសង្គម ដោយអ្នកក្រីក្រមិនអាចចូលទៅនេសាទ បានធ្វើឱ្យមានការផ្លាស់ប្តូរការគ្រប់គ្រង និង ស្ថាប័នពីសម្តេច ហ៊ុន សែន នាយកមន្ត្រី នៅក្នុងឆ្នាំ ២០០១។

គោលបំណងសំខាន់នៃការផ្លាស់ប្តូរគឺអភិវឌ្ឍន៍ប្រព័ន្ធសហគ្រប់គ្រងវិស័យជលផល ប៉ុន្តែមិនទាន់មានច្បាប់ចែងពីសហគមន៍នេសាទ ឬ សហគ្រប់គ្រងជាមួយរដ្ឋាភិបាលនៅឡើយ។ ច្បាប់សព្វថ្ងៃបានចែងជួយដល់នេសាទគ្រួសារតាមរយៈការចែកដាច់ពីការនេសាទ សិប្បកម្ម និង នេសាទឧស្សាហកម្ម។ ប៉ុន្តែ អ្នកក្រីក្រត្រូវនេសាទនូវក៏រិតមួយដែលច្បាប់មិនអនុញ្ញាត ហើយដែលគ្មានមូលដ្ឋានណា ដែលឱ្យអ្នកក្រីក្រគេចចេញពីភាពក្រីក្រក្រៅពីការបង្កើនការនេសាទនោះទេ។

គោលបំណងរបស់ STREAM នៅកម្ពុជាគឺដើម្បីពង្រឹង ឬ អភិវឌ្ឍន៍ និង ទំនាក់ទំនងយុទ្ធសាស្ត្រ ដំណើរការ និង ការអនុវត្តន៍ដែលអាចឱ្យអ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះនៅ តំបន់អាស៊ីប៉ាស៊ីភិចទទួលបាននូវទិសដៅចិញ្ចឹមជីវិតរបស់ខ្លួន។ វាអាចសំរេចទៅបានតាមរយៈការជួយឱ្យមានការយល់កាន់តែច្បាស់ថែមទៀតនូវការចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ ការកសាងសមត្ថភាពរបស់អ្នកផ្តល់សេវាកម្ម ការកែទំរង់ច្បាប់ និង លើកកំពស់ការទំនាក់ទំនង។

គំរោង STREAM នឹងបន្តអនុវត្តការរួបរួមគ្នាជាដៃគូរនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និង ថ្នាក់តំបន់។ រកនូវធនធាន(ថវិកា) ដើម្បីសំរេចបាននូវទិសដៅដែលមានចែងនៅក្នុង CSP ទាំងនេះគឺជាអណត្តិរបស់ STREAM នៅកម្ពុជា។

# III. មាតិកា


I. អារម្ភកថា ii

II. សង្ខេប iv

III. មាតិកា v

១. ភាពក្រីក្រ និង ធនធានវារីជាតនៅក្នុងប្រទេសកម្ពុជា ១

១.១ ភាពក្រីក្រនៃតំបន់ជនបទរបស់ប្រទេសកម្ពុជា ១

១.២ សារៈសំខាន់នៃធនធានវារីជាតចំពោះការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទរបស់ប្រទេសកម្ពុជា ១

១.៣ មូលដ្ឋានធនធានវារីជាតនៅប្រទេសកម្ពុជា ២

២. គោលនយោបាយ និង បរិស្ថានស្ថាប័ននៅកម្ពុជា ៣

២.១ នាយកដ្ឋានជលផល ៣

២.២ សារៈសំខាន់នៃ"ការនេសាទគ្រួសារ" ៣

២.៣ ឱកាសសំរាប់ធ្វើការផ្លាស់ប្តូរ ៣

២.៤ តួនាទីរបស់ទីភ្នាក់ងារផ្តល់ជំនួយខាងក្រៅ ៤

៣. ទិសដៅ ៥

៣.១ គោលដៅ ៥

៣.២ គោលបំណង ៥

៣.៣ លទ្ធផល ៥

៤. យុទ្ធវិធី ៦

៤.១ អភិវឌ្ឍន៍សមត្ថភាពម្នាក់ៗដើម្បីទទួលយកនូវយុទ្ធវិធីចិញ្ចឹមជីវិត ៦

៤.២ អភិវឌ្ឍន៍សមត្ថភាពរបស់ស្ថាប័ន ៦

៤.៣ ជួយដល់ការរៀបចំមាត្រាទី១៥នៃពង្រាងច្បាប់ជលផលថ្មី ៨

៤.៤ ការទំនាក់ទំនង ១០

៥. ភាពជាដៃគូរ ១១

៦. ធនធាន ១២

៧. ឯកសារយោង ១៣

## ១.  ភាពក្រីក្រ  និង  ធនធានវារីជាតនៅក្នុងប្រទេសកម្ពុជា

### ១.១  ភាពក្រីក្រនៃតំបន់ជនបទរបស់ប្រទេសកម្ពុជា

តាមការធ្វើជំរឿននៅឆ្នាំ ១៩៩៨ ប្រជាជនកម្ពុជាមាន១១.៤ លាននាក់ ក្នុងនោះប្រហែល៨២%នៃប្រជាជនរស់នៅជនបទ។ ប្រហែល ៣៦%នៃប្រជាជនកម្ពុជារស់នៅក្រោមខ្សែ បន្ទាត់ភាពក្រីក្រ។ លើផ្នែកសន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស ប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ដែលទាបជាងគេ ២០%។ វាស្ថិតនៅក្នុងចំណោមប្រទេសទាំង ២០ដែលក្រីក្រជាងគេបង្អស់នៅលើពិភពលោក។ ភាពក្រីក្រដាច់ខាតនៅប្រទេសកម្ពុជានៅតែកើតមានទូទាំងប្រទេស ថ្វីត្បិតតែវាបានថយចុះ ៣% នៅចន្លោះពីឆ្នាំ ១៩៩៣ និង ១៩៩៧។ ប្រហែល ៣៦%នៃប្រជាជនកម្ពុជារស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ១៤៥ ដុល្លារ/ម្នាក់/ឆ្នាំ។

នៅតាមខេត្តនិមួយៗមានភាពខុសគ្នាខ្លាំងលើសន្ទស្សន៍សង្គម និង មនុស្សនៃភាពក្រីក្រ និង ការប្រើប្រាស់ធនធានវារីជាត។ សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា (CHDI)ដែលបានប្រមូលផ្តុំនូវសន្ទស្សន៍សង្គម និង សេដ្ឋកិច្ច បានរកឃើញថាខេត្តកំពង់ស្ពឺគឺគ្មានភាពអំណោយផល។ ខេត្តនៅភាគឦសាន (ដូចជាខេត្តរតនៈគិរី និង មណ្ឌលគិរី)ក៏ដូចជាខេត្តកំពង់ចាម សៀមរាប និង ព្រៃវែងក៏មានពិន្ទុអភិវឌ្ឍន៍ធនធានមនុស្សនៅទាបដែរ។

### ១.២  សារៈសំខាន់នៃធនធានវារីជាតចំពោះការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទរបស់ប្រទេសកម្ពុជា

ការគ្រប់គ្រងធនធានវារីជាតសាធារណៈគឺមានសារៈសំខាន់ដល់សុវត្ថិភាពស្បៀង និង ការអភិវឌ្ឍន៍ជនបទនៅកម្ពុជាដោយនិរន្តរភាព។ ឧទាហរណ៍

- ត្រី និង ផលិតផលត្រី (ក្តាម កំពឹស ខ្យង កង្កែប កន្ធេះឡង់) បានរួមចំណែក ៧៥%នៃប្រូតេអ៊ីនសត្វនៅក្នុងចំណីអាហារ និង រុក្ខជាតិក្នុងទឹករួមមាន ត្រកួន ឈូក និង ព្រលិត។
- ការនេសាទគ្រួសារ និង នេសាទតាមវាលស្រែមានចំនួនប្រហែលពី ១៦០.០០០ ទៅ ២៥០.០០០ តោន
- ការនេសាទ និង សកម្មភាពដែលទាក់ទង ជាប្រភពផ្តល់ការងារឱ្យគ្រួសារជនបទក្រីក្រជាង១០% ជាប្រភពនៃប្រាក់ចំណូលជាង៣០%នៃគ្រួសារក្រីក្រជនបទ និង ជាគន្លឹះនៃការចិញ្ចឹមជីវិតរបស់គ្រួសារក្រីក្រជនបទជាង ៩០%
- ការធ្វើចរាចរទៅបឹងទន្លេសាបបានកើតមានឡើងជារៀងរាល់ឆ្នាំ ដើម្បីដោះដូរស្រូវជាមួយត្រីរៀល និង ប្រភេទត្រីតូចៗផ្សេងទៀត ដើម្បីធ្វើប្រហុកដែលជាផ្នែកមួយយ៉ាងសំខាន់នៃសុវត្ថិភាពស្បៀងសំរាប់គ្រួសារកសិករដែលក្រីក្រ។
- ការចាប់ និង ការប្រមូលធនធានវារីជាតដោយអ្នកដែលគ្មានដីធ្លីក្នុង " ខែឃ្លាន " គឺមានសារៈសំខាន់ដល់សុវត្ថិភាពស្បៀង និង ក៏អាចយកទៅលក់ដើម្បីទិញស្រូវផងដែរ
- ក្រុមមនុស្សក្រីក្រដែលប្រើប្រាស់ធនធានវារីជាតថាជាផ្នែកមួយនៃយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ខ្លួនគឺ អ្នកនេសាទគ្រួសារ វារីវប្បករទ្រង់ទ្រាយតូច និង អ្នកប្រមូលធនធានវារីជាត

  អ្នកនេសាទគ្រួសារគឺច្រើនធ្វើនៅតាមទន្លេ បឹង និង តំបន់ព្រៃលិចទឹកនៅ:

  - តាមខេត្តជាប់នឹងបឹងទន្លេសាប: ខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កណ្តាល និង ភាគខាងជើងទីក្រុងភ្នំពេញ

- តំបន់ទន្លេមេគង្គក្រោម និង ទន្លេបាសាក់: ខេត្តកណ្តាលរហូតដល់ភាគខាងត្បូងទីក្រុងភ្នំពេញ កំពង់ចាម ស្វាយរៀង ព្រៃវែង និង តាកែវ
- ផ្នែកខាងលើនៃទន្លេមេគង្គៈ ខេត្តក្រចេះ និង ស្ទឹងត្រែង

វារីវប្បករទ្រង់ទ្រាយតូច និង/ឬ អ្នកប្រមូលធនធានវារីជាតគឺភាគច្រើនមាននៅខេត្តដែលមិនសំបូរធនធានជលផលហើយ ដែលស្ថិតនៅឆ្ងាយពីបឹងទន្លេសាប ទន្លេមេគង្គ និង ទន្លេបាសាក់ ដែលរួមមាន ខេត្ត កំពង់ស្ពឺ រតនៈគិរី មណ្ឌលគិរី ព្រះវិហារ និង ខេត្តឧត្តរមានជ័យ ។

## ១.៣ មូលដ្ឋានធនធានវារីជាតនៅប្រទេសកម្ពុជា

បើប្រៀបធៀបនឹងបណ្តាប្រទេសជិតខាង (ថៃ ឡាវ និងវៀតណាម) កម្ពុជាជាប្រទេសដីតូចមួយ មានផ្ទៃដី ១៨១.០៣៥ គីឡូម៉ែត្រក្រឡា មាន ២៤ ខេត្ត-ក្រុង ដែលក្នុងនោះខេត្ត៣មានព្រំប្រទល់ជាប់នឹងឆ្នេរសមុទ្រមានប្រវែងខ្លី ។ ប្រព័ន្ធទន្លេមេគង្គ ទន្លេបាសាក់ និង បឹងទន្លេសាបបានបង្ករទឹកជន់នៃទំនាបល្បាប់លិចទឹកដីធំនៅភាគកណ្តាលនៃប្រទេសកម្ពុជា ដែលភាគច្រើន នៃប្រជាជនប្រមាណជាង ៨៥% មានជីវភាពរស់នៅអាស្រ័យនឹងទំនាបលិចទឹកនេះ ។

ធនធានវារីជាតិកកើតឡើងក្នុងប្រព័ន្ធអេកូឡូស៊ីនៃទំនាបលិចទឹក គឺដោយរបបទឹកជំនន់ពីទន្លេមេគង្គជារៀងរាល់ឆ្នាំដែលទទួលរងឥទ្ធិពលពីរបបខ្យល់ពីទិសនិរតី (មិថុនា-តុលា) ហើយធ្វើ អោយទំនាបលិច ទឹកនោះមានទំហំ ១០.០០០-១៣.០០០ គ.ម² នៅរដូវវស្សាគ្របដណ្តប់តាមបណ្តាទន្លេ និងដៃរបស់វា បឹងទន្លេសាប និង ទន្លេបាសាក់។ នៅ រដូវប្រាំងរបបទឹក ទន្លេសាបបានហូរចូលទៅទន្លេមេគង្គ ផ្ទុយទៅវិញនៅរដូវវស្សា ទឹកទន្លេមេគង្គបានហូរចូលទៅក្នុងបឹងទន្លេសាបវិញ ។

នេសាទទឹកសាបកម្ពុជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងសុវត្ថិភាពស្បៀង និង សេដ្ឋកិច្ចជាតិ ជាងបណ្តាប្រទេសនានានៅលើពិភពលោក ។ នេសាទទឹកសាបកម្ពុជាបានផ្តល់ទិន្នផលត្រីប្រចាំឆ្នាំជាមធ្យម ២៩០.០០០-៤៣០.០០០ តោន ដែលជាប់ចំណាត់ថ្នាក់លេខ៤នៅលើពិភពលោកខាងការសំបូរត្រីទឹកសាប ។ ទិន្នផលត្រីទាំងនេះគិតជាប្រាក់មានតំលៃ ១០០-២០០ លានដុល្លារអាមេរិក (តំលៃនៅទីកន្លែងនេសាទ)។ បើគិតជាតំលៃ នៅតាមទីផ្សារ មានតំលៃជាទឹកប្រាក់ចំនួន ២៥០-៥០០ លានដុល្លារអាមេរិក ដែលចូលរួមវិភាគទានប្រមាណ ៩%-១៨% នៃផលិតផលក្នុងស្រុកសរុប (GDP) ។

## ២. គោលនយោបាយ និង បរិស្ថានស្ថាប័ននៅកម្ពុជា

### ២.១ នាយកដ្ឋានជលផល

នាយកដ្ឋានជលផល (DoF) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧៩។ គោលបំណងសំខាន់គឺ គ្រប់គ្រង និង ចាត់ចែងដែន នេសាទ (ដែលត្រូវបានគេគិតថាជាកម្មសិទ្ធិរបស់រដ្ឋ) ដោយរួមបញ្ចូលទាំងការគ្រប់គ្រងនិងចាត់ចែងឡូតិ៍បំរុងចំនួន ១៥ផង។ ជាក់ស្តែង ការគ្រប់គ្រង និង ចាត់ចែងដែននេសាទគឺផ្តោតជាសំខាន់ទៅលើការកំណត់ធ្វើនេសាទ តាមរយៈការចាត់ថ្នាក់ប្រភេទ ឧបករណ៍ទៅតាមទំហំដែលអនុញ្ញាតឱ្យធ្វើនេសាទៈ នេសាទគ្រួសារ នេសាទសិប្បកម្ម និង នេសាទឧស្សាហកម្ម។ វារីវប្បកម្ម និង ផ្សព្វផ្សាយជលផលគឺមិនទាន់មានការសំរបសំរួល ហើយពឹងផ្អែកយ៉ាងខ្លាំងពីគំរោងជំនួយដូចជា កម្មវិធីវារីវប្បកម្មរបស់វិទ្យាស្ថាន បច្ចេកវិទ្យាអាស៊ី និង សកម្មភាពរបស់ NGOs នានា។

### ២.២ សារៈសំខាន់នៃ "ការនេសាទគ្រួសារ "

ច្បាប់សព្វថ្ងៃបានចែងពី "នេសាទគ្រួសារ " ដែលចែកដាច់ពីការនេសាទសិប្បកម្ម និង នេសាទឧស្សាហកម្ម។ និយមន័យនៃ "នេសាទគ្រួសារ "គឺផ្អែកទៅលើប្រភេទ និង ទំហំឧបករណ៍នេសាទដែលប្រើ។ ការនេសាទគ្រួសារគឺមិនចាំបាច់សុំទិដ្ឋាការទេ ហើយអាច នេសាទបានពេញមួយឆ្នាំនៅគ្រប់កន្លែង (លើកលែងតែឡូតិ៍បំរុង)។ វាជាការសំខាន់ដែលត្រូវសង្កត់ទៅលើការនេសាទនៅក្នុងនាទី ឡូតិ៍ នៅរដូវបើកនេសាទអ្នកនេសាទគ្រួសារអាចនេសាទបាននៅតំបន់ពិសេសសំរាប់ប្រជាជន ហើយនេសាទបាននៅក្នុងនាទីឡូតិ៍ក្នុង រដូវបិទនេសាទ។ ប៉ុន្តែ ការធ្វើឯកជនភាវូបនីយកម្មនៃជលផលទឹកសាបជាតិ (ឡូតិ៍នេសាទ) បានធ្វើឱ្យអ្នកនេសាទគ្រួសារមានជំលោះ ជាមួយថៅកែឡូតិ៍ដែល ទោះបីជាមានច្បាប់ក៏ដោយក៏ពួកគេមិនឱ្យអ្នកនេសាទគ្រួសារចូលនេសាទដែរ តាមរយៈ ការគំរាមកំហែង ប្រើអំពើហិង្សា និង សម្លុតដាក់គុក។

ជាងនេះទៅទៀត និយមន័យនៃ "នេសាទគ្រួសារ " គឺមិនផ្អែកទៅលើកំរិតនៃការចាប់ដែលអនុញ្ញាតឱ្យពួកគេអាចរស់បាន នោះទេ ប៉ុន្តែទៅលើប្រភេទឧបករណ៍នេសាទដែលប្រើប្រាស់ដោយអ្នកនេសាទគ្រួសារដែលបានចែងតាំងពីសម័យអាណានិគមម្ល៉េះ ។ ជាក់ស្តែង ប្រការនេះបានបង្ខំឱ្យអ្នកក្រីក្រត្រូវនេសាទនូវកំរិតមួយដែលច្បាប់មិនអនុញ្ញាតដើម្បីធ្វើការចិញ្ចឹមជីវិត។ បន្ថែមលើនេះ ទៀត និយមន័យនៃ "នេសាទគ្រួសារ " មិនអនុញ្ញាតឱ្យអ្នកនេសាទគ្រួសារលក់ត្រី ដូច្នេះច្បាប់បច្ចុប្បន្នមិនបានផ្តល់នូវមូលដ្ឋានណា សំរាប់ឱ្យអ្នកក្រីក្រគេចចេញពីភាពក្រីក្រក្រៅពីការបង្កើននូវកំរិតចាប់នោះឡើយ។

### ២.៣ ឱកាសសំរាប់ធ្វើការផ្លាស់ប្តូរ

ការរំជើបរំជួលនៅក្នុងសង្គមទាក់ទងនឹងការគ្រប់គ្រង និង ចាត់ចែងដែននេសាទបានក្លាយទៅជាបញ្ហាចំរូងចំរាស់មួយនៅក្នុង ប្រទេសកម្ពុជា ដោយអ្នកក្រីក្រមិនអាចចូលទៅនេសាទបាន។ ជាការឆ្លើយតប នៅក្នុងឆ្នាំ ២០០១ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី បានធ្វើការប្រកាសជាសាធារណៈពីគោលបំណងរបស់គាត់ក្នុងការផ្លាស់ប្តូរស្ថាប័ន។ ដែលក្នុងនោះរួមមានទាំងការកាត់ឡូតិ៍នេសាទ និង ជំនួសតំណែងប្រធាននាយកដ្ឋានជលផលដោយអនុប្រធានរបស់គាត់ និង ការបង្កើតនូវការិយាល័យថ្មីនៅ DoF គឺការិយាល័យ អភិវឌ្ឍន៍សហគមន៍នេសាទដើម្បីជួយដល់ការអភិវឌ្ឍន៍សហគមន៍នេសាទ។

បន្ទាប់ពីមានអនុសាសន៍របស់សម្តេច ហ៊ុន សែន មក អនុក្រឹត្យចំនួន ១២ ត្រូវបានគេប្រកាសដើម្បីកាត់ឡូតិ៍នេសាទ។ ឡូតិ៍ នេសាទដែលមានតំលៃទាបជាង ៣០ លានរៀល ហើយឡូតិ៍ខ្លះដែលមានតំលៃរហូតដល់ ៣០០ លានរៀលដែលមានជំលោះច្រើន

ក៏ត្រូវបានលុបចោលដែរ។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រសួង ជលផលខេត្ត និង ម្ចាស់ឡូតិ៍រួចមក ពង្រាងអនុក្រឹត្យដែលបញ្ជាក់ច្បាស់លាស់ពីដំណើរការដេញថ្លៃឡូតិ៍ត្រូវបានធ្វើបញ្ចប់ ។ ជាថ្មីម្តងទៀត បន្ទាប់ពីអនុសាសន៍របស់សម្តេច ហ៊ុន សែន អនុក្រឹត្យស្តីពីការលុបចោលនៅថ្លៃឈ្នួលនេសាទ (ដែលតែងតែអនុវត្តទាក់ទងទៅនឹងករិតចាប់)។ ការជះឥទ្ធិពលនៃការផ្លាស់ប្តូរលើប្រាក់ចំណូល និង ចំណាយរបស់ DoF គឺនៅតែមិនច្បាស់លាស់។

ច្បាប់ជលផលក៏ត្រូវបានគេធ្វើការកែប្រែដែរ។ ពង្រាងទីមួយត្រូវបានគេបញ្ជូនទៅឱ្យការិយាល័យជលផល និងមន្ទីរកសិកម្មខេត្តដើម្បីធ្វើការផ្តល់មតិ។ មាត្រាទី ៧៦ ៧៧ និង ៧៨ នៃពង្រាងច្បាប់ថ្មីទាក់ទងនឹងសហគ្រប់គ្រង និង សំណើធ្វើអនុក្រឹត្យថ្មីស្តីពីសហគមន៍នេសាទត្រូវបានបញ្ជូនទៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ មុនពេលបញ្ជូនទៅនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា។ ប៉ុន្តែមាត្រាទី ១៥ នៃពង្រាងច្បាប់ថ្មីនៅតែថែងពីនេសាទគ្រួសារ និងមិនអនុញ្ញាតឱ្យលក់ត្រី ខណៈដែលអនុក្រឹត្យបានឆ្លងកាត់ការកែប្រែ ៥០លើកក្នុងរយៈពេល២ឆ្នាំដោយគ្មានដំណោះស្រាយ ឬ អាចអនុម័តទៅជាច្បាប់។

## ២.៤ តួនាទីរបស់ទីភ្នាក់ងារផ្តល់ជំនួយខាងក្រៅ

AIT Outreach, MRC, FAO និង NGOs ដូចជា Oxfam មានវត្តមាននៅប្រទេសកម្ពុជាជាយូរមកហើយ។ មានការផ្តោតការយកចិត្តទុកដាក់លើការស្វែងយល់ពីវិសាលភាព និង ឌីណាមិចនៃវិស័យជលផល ស្ថានភាពរបស់ប្រជាជនក្រីក្រដែលនេសាទ ក៏ដូចជាការធ្វើអន្តរាគមន៍ដែលផ្តោតទៅលើវារីវប្បកម្ម។ ការជួយគាំទ្រ និង ការលើកកំពស់ការយល់ដឹងបានដើរតួនាទីក្នុងការជំនះយុទ្ធសាស្ត្រគ្រប់គ្រងវិស័យជលផល និង នាំឱ្យមានការផ្លាស់ប្តូរ។ ទីភ្នាក់ងារផ្តល់ជំនួយខាងក្រៅភាគច្រើនមានការពិបាកក្នុងការឆ្លើយតបជាបន្ទាន់នូវការលំបាកនេះ។ មាន NGOs តូចៗប្រហែល៣០បានធ្វើការជួយលើផ្នែកផ្សេងៗដល់សហគមន៍នេសាទ។ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជាបានប៉ុនប៉ងធ្វើការវាយតំលៃពីវឌ្ឍនភាព ថ្វីត្បិតតែពតិមានជាក់លាក់ពីវឌ្ឍនភាព និង យុទ្ធសាស្ត្រនៅមានករិតក៏ដោយ។ ឧទាហរណ៍ កម្មវិធីអភិវឌ្ឍន៍តំបន់អាស៊ីអគ្នេយ៍ ( SADP) ដែលធ្វើការជាមួយគណៈកម្មការទន្លេមេគង្គដើម្បីជួយដល់ការអភិវឌ្ឍន៍សហគមន៍នេសាទនៅក្នុងឡូតិ៍ដែលកាត់ចេញ៣ នៅក្នុងខេត្តកំពង់ឆ្នាំង។ ការប្រឈមមុខដែលកើតមានឡើងរួមមាន តើអ្វីដែលអាច និង មិនអាចធ្វើបានបើប្រៀបធៀបទៅនឹងអ្វីដែលអនុញ្ញាតជាផ្លូវការ និង ការអនុវត្តន៍ផ្សេងគ្នារវាងឡូតិ៍ដែលកាត់ឱ្យ និង តំបន់ដែលជាតំបន់សាធារណៈ។

ភ្នាក់ងារផ្តល់ជំនួយអន្តរជាតិដ៏ទៃទៀតដូចជា FAO ដែលបានធ្វើការនៅខេត្តសៀមរាបលើការគ្រប់គ្រងធនធានធម្មជាតិ (រួមទាំងជលផលផង) អស់រយៈពេលជាច្រើនឆ្នាំ និង ធនាគារពិភពលោកដែលបានផ្តល់ជំនួយតាមរយៈកម្មវិធីលើកកំពស់ផលិតកម្មកសិកម្មក្នុងទំរង់ជាការប្រឹក្សាលើការកែទំរង់ស្ថាប័ន និង ការកែប្រែច្បាប់ជលផល។

សហគមន៍អឺរ៉ុបបានប្រកាសផ្តល់កញ្ចប់ជំនួយថ្មីមានរយៈពេល៣ឆ្នាំមានទឹកប្រាក់ ៦៨,៧ លានអឺរ៉ូ (ប្រហែល ៦២ លានដុល្លារអាមេរិក) ក្នុងខែឧសភា ២០០២ ដើម្បីជួយដល់ការអភិវឌ្ឍន៍ជនបទនៅប្រទេសកម្ពុជា។ ជំនួយនេះនឹងផ្តោតទៅលើការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការគ្រប់គ្រងទឹក និង ដំណាំចំរុះ បណ្តុះបណ្តាលវិជ្ជាជីវៈ និង ការកំចាត់មីន។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានយល់ព្រមផ្តល់ប្រាក់កម្ចីលើផ្នែកនេះដែរប៉ុន្តែធ្វើតែនៅតំបន់បឹងទន្លេសាប។ អង្គការ IDRC និង World Fish Center ក៏បានពិចារណាលើការជួយលើគំរោងស្រាវជ្រាវតូចៗផងដែរ។

## ៣. ទិសដៅ

### ៣.១ គោលដៅ

ទិសដៅរបស់ STREAM កម្ពុជាគឺ: អ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះនៅកម្ពុជាអាចសំរេចនូវទិសដៅចិញ្ចឹមជីវិតរបស់ខ្លួន។

### ៣.២ គោលបំណង

គោលបំណងរបស់ STREAM កម្ពុជាគឺ ដើម្បីពង្រឹង ឬ អភិវឌ្ឍន៍ និង ទំនាក់ទំនងយុទ្ធសាស្ត្រ ដំណើរការ និង ការអនុវត្តន៏ដែលអាចឱ្យអ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះនៅកម្ពុជាអាចសំរេច នូវទិសដៅចិញ្ចឹមជីវិតរបស់ខ្លួន ដោយផ្តោតជាសំខាន់នៅខេត្ត កំពង់ឆ្នាំង កណ្តាល និង ក្រចេះ។

### ៣.៣ លទ្ធផល

STREAM កម្ពុជានឹងសំរេចនូវលទ្ធផលដូចខាងក្រោម:

១. មន្ត្រីការិយាល័យជលផល និង មន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង កណ្តាល និង ក្រចេះ និង មន្ត្រីនៅកម្មវិធី SCALE និង CFDO មានការយល់ដឹងពីការចិញ្ចឹមជីវិតរបស់អ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះកាន់តែប្រសើរ

២. NGOs ក្រុមសហគមន៏ និង មន្ត្រីការិយាល័យជលផល និង មន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង កណ្តាល និង ក្រចេះ និង មន្ត្រីនៅកម្មវិធី SCALE និង CFDO ជួយដល់ទិសដៅចិញ្ចឹមជីវិតរបស់អ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះ កាន់តែប្រសើរ

៣. ការរៀបចំមាត្រាទី១៥នៃពង្រាងច្បាប់ជលផលថ្មីឆ្លើយតបដល់ទិសដៅចិញ្ចឹមជីវិតរបស់អ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាត ដែលងាយរងគ្រោះនៅកម្ពុជាកាន់តែប្រសើរ

៤. ការទំនាក់ទំនងក្នុងចំណោមអ្នកក្រីក្រ និង អ្នកប្រើប្រាស់ធនធានវារីជាតដែលងាយរងគ្រោះ អ្នកផ្តល់សេវាកម្ម ស្ថាប័ន និង អ្នកធ្វើគោលនយោបាយកាន់តែប្រសើរ

## ៤. យុទ្ធវិធី

មានការយល់ច្រលំពីច្បាប់ជលផល រដ្ឋបាលជលផល (ជាពិសេសគោលគំនិតពីការគ្រប់គ្រងសហគមន៍ និង តួនាទី និង ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ និង សហគមន៍ដែលទាក់ទង)និង ដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍ស្ថាប័ន ចាំបាច់ដើម្បីជួយដល់ការគ្រប់គ្រងសហគមន៍។ តំរូវការជំនួយគឺមានភាពធំធេង និង គំរោង STREAMតែម្នាក់ឯងមិនអាចដោះស្រាយបានទេ។ ក្នុងបរិបទនេះ ជាការសំខាន់ដែលត្រូវសង្កត់ពីសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ធនធានវារីជាតដែលក្រីក្រគឺ សិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ធនធានត្រូវបានធានា និង ស្ថាប័នថ្នាក់មូលដ្ឋាន និង ជាតិផ្តល់នូវសេវាកម្មសមស្រប។ ដោយមានគំនិតនេះ STREAM នឹងផ្តោតការជួយឧបត្ថម្ភរបស់ខ្លួនលើអាទិភាពដូចខាងក្រោមៈ

### ៤.១ អភិវឌ្ឍន៍សមត្ថភាពថ្នាក់ៗដើម្បីទទួលយកនូវយុទ្ធវិធីចិញ្ចឹមជីវិត

សមត្ថភាពរបស់មន្ត្រីជលផលក្នុងការស្វែងយល់ពីការចិញ្ចឹមជីវិតរបស់អ្នកក្រីក្រប្រើប្រាស់ធនធានធម្មជាតិគឺមានសារៈសំខាន់ បើសិនជា ការអភិវឌ្ឍន៍យុទ្ធសាស្រ្ត ដំណើរការ និង ការអនុវត្តន៍ការគ្រប់គ្រងធនធានវារីជាតឆ្លើយតបយ៉ាងត្រឹមត្រូវទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនដែលមិនទទួលបានផលប្រយោជន៍។ ប៉ុន្តែសមត្ថភាពរបស់ CFDO និងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតក្នុងការទទួលយកនូវយុទ្ធវិធីចិញ្ចឹមជីវិតគឺនៅមានកំរិត ដោយមានមន្ត្រី ២ ឬ ៣ នាក់ធ្លាប់មានបទពិសោធន៍ ឬជំនាញដែលចាំបាច់ដើម្បីវិភាគ និង យល់ពីការចិញ្ចឹមជីវិតរបស់អ្នកក្រីក្រប្រើប្រាស់ធនធានវារីជាត។

STREAMនឹងធ្វើការដើម្បីបង្កើនសមត្ថភាពមន្ត្រីរដ្ឋាភិបាលឱ្យចេះធ្វើការវិភាគពីការចិញ្ចឹមជីវិត។ វានឹងផ្តោតជាពិសេសទៅលើការជួយឧបត្ថម្ភដល់មន្ត្រីជលផល និង មន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង កណ្តាល និង ក្រចេះដែលតំណាងឱ្យតំបន់នេសាទនៅផ្នែកខាងលើទន្លេមេគង្គ ទន្លេសាប និង ផ្នែកខាងក្រោមទន្លេមេគង្គ។ យុទ្ធវិធីនេះនឹងធានាថា ការវិនិយោគអភិវឌ្ឍន៍ធនធានមនុស្សរបស់ STREAM គឺនៅក្រៅពីទីក្រុងភ្នំពេញទៅទៀត។

STREAM នឹងធ្វើការងារនេះជាមួយដៃគូរបស់ខ្លួនគឺ កម្មវិធី SCALE។ វាបានចាប់ផ្តើមនៅក្នុងខែមករា ២00១ ក្រោមកម្មវិធីគ្រប់គ្រងធនធានវារីជាតរបស់ DFID។ ការជួយឧបត្ថម្ភនេះបានបន្តក្រោម STREAM នឹងនៅតែជាផ្នែកមួយសំខាន់នៃការអនុវត្តន៍ CSP។

នៅពេលដែលឱកាសមាន STREAMនឹងជួយដល់ក្រុមចិញ្ចឹមជីវិតខេត្តដើម្បីធ្វើការជាមួយសហគមន៍ដើម្បីអភិវឌ្ឍន៍គំរោងសាកល្បងសហគមន៍ ដោយផ្អែកទៅលើលទ្ធផលដែលទទួលបានពីការវិភាគការចិញ្ចឹមជីវិត។ វាអាចរួមបញ្ចូល ការផ្តល់នូវរចនាសម្ព័ន្ធ និង/ឬ ការជួយកសាងសមត្ថភាពបច្ចេកទេសដល់ NGOsមូលដ្ឋាន និង ក្រុមសហគមន៍នៅក្នុងសហគមន៍គោលដៅនិមួយៗ (៤.២.៣ ខាងក្រោម)។ ក្នុងរយៈពេលយូរ STREAM នឹងជួយដល់ក្រុមចិញ្ចឹមជីវិតឱ្យប្រើប្រាស់នូវទេពកោសល្យ បទពិសោធន៍ និង ចំណេះដឹងដើម្បីបង្កើនការយល់ដឹង និង អភិវឌ្ឍន៍មន្ត្រីរដ្ឋាភិបាលនៅខេត្តផ្សេងៗទៀត។

### ៤.២ អភិវឌ្ឍន៍សមត្ថភាពរបស់ស្ថាប័ន

#### ៤.២.១ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (CFDO)

នៅពេលចាប់ CFDOគ្មានការិយាល័យ គ្មានសំភារៈ គ្មានមន្ត្រីដែលមានសមត្ថភាព គ្មានផែនការយុទ្ធសាស្ត្រ គ្មានប្រព័ន្ធការិយាល័យ និង គ្មានថវិកា។ មន្ត្រីត្រូវបានផ្ទេរមកពីការិយាល័យនានាដោយមន្ត្រីគ្រប់គ្រង។ មន្ត្រីដែលមានសមត្ថភាពបានធ្វើការ

ជាមួយគំរោងអ្នកផ្តល់ជំនួយដែលគេទទួលបាននូវប្រាក់ឧបត្ថម្ភដែលចាំបាច់ដើម្បីរស់ ចំណែកឯមន្ត្រីដែលចូលថ្មី មានប្រាក់ឧបត្ថម្ភតិចតួចដោយគ្មានថវិការបាយការណ៍ និងគ្មានការងារធ្វើហើយតែងតែមិនមកធ្វើការ ។

កសាងសមត្ថភាពរបស់ CFDO ដើម្បីអនុវត្តនូវការកែទំរង់វិស័យជលផលគឺជាអាទិភាពមួយរបស់នាយកដ្ឋានជលផល ។ STREAM អាចឆ្លើយតបយ៉ាងឆាប់រហ័សនូវសំណើពីប្រធាននាយកដ្ឋានជលផលដើម្បីផ្តល់ការកសាងសមត្ថភាពដល់ CFDO ។ STREAM បានផ្តល់ដល់ CFDO នូវទីប្រឹក្សាគ្រប់គ្រងម្នាក់ពី *Accenture*(ជ្រើសរើសក្រោមគំរោងដៃគូររបស់ VSO) ។ ទីប្រឹក្សាបានផ្តល់នូវការជួយជ្រោមជ្រែងដល់ CFDO នៅកំរិតមួយដែលស្មើជាមួយនឹងមន្ត្រី ហើយអ្នកឱ្យយោបល់បណ្តោះអាសន្នមិនអាចធ្វើបាន ហើយទីប្រឹក្សាបានជួយសំរួលដល់ការអភិវឌ្ឍន៍រចនាសម្ព័ន្ធការិយាល័យ ការវាយតំលៃសមត្ថភាពរបស់មន្ត្រី ផែនការយុទ្ធសាស្ត្រ និង ការងាររបស់ CFDO ។

ការជួយឧបត្ថម្ភនេះនឹងបន្ត ហើយដែលចាំបាច់ដើម្បីសរសេរនូវ CSP និង រយៈពេលមធ្យម ។ យើងមានហេតុផលដែលថាផ្នែកសហគមន៍នេសាទនៅកម្ពុជានឹងទទួលបាននូវការជួយឧបត្ថម្ភពីអ្នកផ្តល់ជំនួយកើនឡើងថែមទៀតក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ។ ឥឡូវនេះយើងត្រូវឈានមួយជំហានដើម្បីធានាថា CFDO មានសមត្ថភាពសំរបសំរួលសកម្មភាពដែលបានផ្តល់ជំនួយមកពីទីភ្នាក់ងារផ្តល់ជំនួយនានា បើសិនជាធនធានទាំងនេះត្រូវបានប្រើប្រាស់ឱ្យមានប្រសិទ្ធិភាព និង ចំគោលដៅ ហើយការផ្លាស់ប្តូរនូវបទពិសោធន៍ដើម្បីឈានទៅរកទិសដៅរួមមួយ ។ STREAMនឹងនៅតែរក្សានូវការជួយឧបត្ថម្ភដ៏មានកំរិតរបស់ខ្លួនដល់ CFDO ហើយនឹងបញ្ឈប់ការជួយឧបត្ថម្ភ បើសិន និង នៅពេលណាដែលមានការជួយឧបត្ថម្ភដល់ស្ថាប័នពីទីភ្នាក់ងារអភិវឌ្ឍន៍នានាចេះតែមានការកើនឡើង (ឧទាហរណ៍ ADB) ។

### ៤.២.២ ការិយាល័យជលផលខេត្ត

សមត្ថភាពរបស់ការិយាល័យជលផលខេត្តក្នុងការអនុវត្តន៍នូវការកែទំរង់វិស័យជលផលគឺជាចំណុចសំខាន់មួយទៀត ។ ការធ្វើវិមជ្ឈការសមត្ថភាពនៅថ្នាក់ខេត្តដើម្បីភ្ជាប់ជាមួយនឹង CFDO គឺមានសារៈសំខាន់ដើម្បីឱ្យវិស័យនេះមានដំណើរការល្អ និង ងាយអភិវឌ្ឍន៍ប្រព័ន្ធសហគ្រប់គ្រង ។ នឹងស្វែងរកការជួយឧបត្ថម្ភនេះ បន្តពីការកសាងសមត្ថភាពរបស់ CFDO ។ ការអភិវឌ្ឍន៍ និង ការលើកកំពស់ការប្រមូលទិន្នន័យ និង ចែករំលែកយន្តការនៃសហគ្រប់គ្រងគឺជាទិសដៅដំបូងរបស់ CFDO ដោយធ្វើការជាមួយការិយាល័យជលផលខេត្តដែលជាដៃគូរអនុវត្ត យន្តការសាកល្បងមួយដែលរកនូវពតិមានចាំបាច់ និង ប្រព័ន្ធសំរាប់ប្រមូល ចែករំលែក និង បទពិសោធ៍ថ្មីៗពីសហគ្រប់គ្រង និង សហគមន៍នេសាទ ។

### ៤.២.៣ អង្គការសង្គមស៊ីវិល

ការទទួលយកនូវយុទ្ធសាស្ត្រចិញ្ចឹមជីវិតដោយនាយកដ្ឋានជលផល និង ស្ថាប័នផ្សេងៗទៀតបានផ្តល់នូវសក្តានុពលសំរាប់អ្នកក្រីក្រប្រើប្រាស់ធនធានវារីជាតមានឥទ្ធិពលកាន់តែខ្លាំងឡើងថែមទៀតលើយុទ្ធសាស្ត្រ ដំណើរការ និង ការអនុវត្តន៍ដែលជះឥទ្ធិពលលើជីវិតរបស់ពួកគេ ។ ការកាត់ឡូតិ៍នេសាទយ៉ាងច្រើនក៏បានផ្តល់ឱកាសឱ្យអ្នកក្រីក្រប្រើប្រាស់ធនធានវារីជាតមានសិទ្ធិត្រួតត្រាលើធនធានកាន់តែខ្លាំង ។

ប៉ុន្តែ បទពិសោធនៅតំបន់អាស៊ីប៉ាស៊ីភិចបានបង្ហាញថា អ្នកក្រីក្រប្រើប្រាស់ធនធានវារីជាតជាច្រើនមិនអាចឆក់យកឱកាសនេះបានដោយសារតែគ្មានតំណាងសហគមន៍ និង/ឬ សមត្ថភាពបច្ចេកទេសនៅទាប ។ ត្រូវពង្រឹងស្ថាប័ន និង/ឬ សមត្ថភាពបច្ចេកទេសរបស់

NGOs និងក្រុមសហគមន៍ ជាពិសេសបើសហគមន៍មូលដ្ឋានដើរតួនាទីយ៉ាងមានប្រសិទ្ធភាពក្នុងការលើកកំពស់អភិបាលកិច្ចល្អ ការគ្រប់គ្រងសហគមន៍មាននិរន្តរភាព និង ការលេចឡើងនូវនិន្នាការយកយុទ្ធសាស្ត្រប្រជាជនជាធំគឺនៅតែឋិតថេរនៅប្រទេសកម្ពុជា ។

មកទល់សព្វថ្ងៃនេះ ការជួយឧបត្ថម្ភភាគច្រើនរបស់ STREAM ទៅលើសង្គមស៊ីវិលគឺ កម្មវិធី SCALE ។ នេះគឺដោយសារការកម្មវិធីនេះមានដៃគូរជាមួយនាយកដ្ឋានជលផល ជាពិសេសជាមួយ CFDO ។ STREAM ប្តេជ្ញាពង្រឹងនូវភាពជាដៃគូរនេះរហូតដល់ចប់ការអនុវត្តន៍ CSPនេះ ហើយនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយ CFDO និង SCALE ដើម្បីធានាឱ្យបានសំរេច។ តំរូវការពិតប្រាកដនឹងលេចឡើងនៅពេលដែលភាពជាដៃគូរកាន់តែរីកចំរើនឡើង ប៉ុន្តែនៅពេលខាងមុខគេនឹងផ្តល់ឱ្យនូវទីប្រឹក្សាបច្ចេកវិទ្យាពតិមាន និង ជលផល ដែលនឹងត្រូវធ្វើការជាមួយស្ថាប័នទាំងពីរដើម្បីអភិវឌ្ឍន៍មូលដ្ឋានទិន្នន័យសហគមន៍នេសាទរួមគ្នា។

នៅក្នុងរយៈពេលយូរ STREAM ប្តេជ្ញាអភិវឌ្ឍន៍សមត្ថភាពផ្នែកផ្សេងៗទៀតនៃសង្គមស៊ីវិល ជាពិសេស NGOs និង ក្រុមសហគមន៍នៅថ្នាក់មូលដ្ឋាន។ ជាពិសេស វានឹងធ្វើដោយឈរលើលទ្ធផលនៃការវិភាគការចិញ្ចឹមជីវិតនៅខេត្ត កំពង់ឆ្នាំង កណ្តាល និង ក្រចេះ។ នៅពេលដែលតំរូវការកសាងសមត្ថភាពបច្ចេកទេស និង ស្ថាប័នត្រូវបានកំណត់ដោយសហគមន៍មូលដ្ឋាន STREAM នឹងប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីជួយដល់ក្រុមចិញ្ចឹមជីវិត និង ដៃគូររបស់ STREAM ធ្វើការជាមួយសហគមន៍មូលដ្ឋានដើម្បីអភិវឌ្ឍន៍ និង អនុវត្តផែនការដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការនេះ។

## ៤.៣ ជួយដល់ការរៀបចំមាត្រាទី១៥នៃពង្រាងច្បាប់ជលផលថ្មី

### ៤.៣.១ ដំណើរការធ្វើគោលនយោបាយ

ជាការរួមវិភាគទានដល់ការលើកកំពស់ការស្វែងយល់ពីដំណើរការធ្វើគោលនយោបាយពីវិស័យជលផលនៅកម្ពុជា ជាពិសេសទាក់ទងនឹងតើអ្នកធ្វើការសំរេចចិត្តសំខាន់ៗណាដែលអាចមានឥទ្ធិពលដល់ការផ្លាស់ប្តូរច្បាប់ជលផល STREAMនឹងសើរើពីដំណើរការអភិវឌ្ឍន៍អនុក្រឹត្យស្តីពីសហគមន៍នេសាទ ដែលរួមមានការកែប្រែអនុក្រឹត្យពីពេលមួយទៅពេលមួយទៀត ដោយធ្វើសម្ភាន៍ ជាមួយអ្នកផ្តល់ពត៌មានសំខាន់ៗ និង អ្នកចូលរួមក្នុងដំណើរការ និង ធ្វើការស្រាវជ្រាវផ្សេងៗទៀតរហូតដល់បញ្ហាក្នុងវិស័យជលផលនៅ កម្ពុជា ។ លទ្ធផលនៃការសើរើនឹងដាក់បញ្ចូលទៅក្នុងឯកសារដែលពិនិត្យមើលលើពង្រាង (មានជាង៥០ពង្រាង) និង រកនូវចំណុច ផ្លាស់ប្តូរ តើមានស្ថាប័នណាខ្លះដែលចូលរួម ហើយតើនរណាមានឥទ្ធិពលលើការផ្លាស់ប្តូរនេះ។ យើងជឿជាក់ថាការកើនឡើងចំណេះដឹងនឹងបង្កើនសមត្ថភាពដៃគូររបស់ STREAM ជាប់ទាក់ទងជាមួយនឹងដំណើរការធ្វើច្បាប់នៅប្រទេសកម្ពុជា ហើយជាពិសេសជួយដល់ការរៀបចំសាជាថ្មីមាត្រាទី១៥ នៃច្បាប់ជលផលថ្មី។

### ៤.៣.២ លើកកំពស់ការប្រើប្រាស់ការងារទាក់ទងការចិញ្ចឹមជីវិតដែលមានស្រាប់នៅប្រទេសកម្ពុជា

ថ្វីត្បិតតែ STREAMបានជួយដល់ការដឹកនាំធ្វើវិភាគពីការចិញ្ចឹមជីវិតក្នុងខេត្ត កំពង់ឆ្នាំង កណ្តាល និង ក្រចេះ វាជាការចាំបាច់ត្រូវលើកឡើងពីគោលបំណងសំខាន់របស់វាគឺលើកកំពស់សមត្ថភាពរបស់ក្រុមចិញ្ចឹមជីវិត មិនមែនផ្តល់នូវពត៌មានវិភាគត្រឹមត្រូវនោះទេ។ ប៉ុន្តែ ទាំងឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង លោកប្រធាននាយកដ្ឋានជលផលបានលើកឡើងពីបំណងរបស់ពួកគាត់ក្នុងការប្រើប្រាស់នូវពត៌មានដែលបានមកពីការវិភាគនេះដើម្បីគាំទ្រដល់ការរៀបចំសាជាថ្មីនូវមាត្រាទី១៥ នៃច្បាប់ជលផលថ្មី។

នេះបង្ហាញនូវតំរូវការនូវពត៌មានពីការរស់នៅរបស់អ្នកនេសាទក្រីក្រដើម្បីគាំទ្រដល់ការកែប្រែច្បាប់ ក៏ដូចជាកង្វះខាតនៃការវិភាគការចិញ្ចឹមជីវិតនៅប្រទេសកម្ពុជា។ វាជាការពិតដែលថាការធ្វើវិភាគពីការចិញ្ចឹមជីវិតមានតិចតួចនៅប្រទេសកម្ពុជា យើងត្រូវទទួលស្គាល់ថាសកម្មភាពដែលបានធ្វើដោយអង្គការផ្សេងៗ អាចផ្តល់នូវពត៌មានច្រើនថែមទៀតពីការរស់នៅរបស់អ្នកនេសាទ និង កសិករនៅប្រទេសកម្ពុជា។

STREAM នឹងប្រើប្រាស់ការងារនេះដើម្បីគាំទ្រដល់ការរៀបចំច្បាប់សាជាថ្មី ដោយធ្វើការសើររើនៅនឹងកន្លែងនូវពត៌មានបន្ទាប់បន្សំដែលមានរួចមកហើយនៅប្រទេសកម្ពុជា។ ការងារនេះរួមមាន ការធ្វើសម្ភាសន៍ជាមួយអ្នកជាប់ពាក់ពន្ធ័សំខាន់ៗ និង អ្នកចូលរួមនៅក្នុងការងារដែលទាក់ទងការចិញ្ចឹមជីវិតក្នុងវិស័យជលផល។ លទ្ធផលដែលទទួលបាននេះនឹងគាំទ្រដល់លទ្ធផលការវិភាគការចិញ្ចឹមជីវិតដែលបានធ្វើនៅក្នុងខេត្ត កំពង់ឆ្នាំង កណ្តាល និង ក្រចេះ ដើម្បីផលិត " ប្រមូលផ្តុំ " រូបភាពនៃការរស់នៅរបស់អ្នកក្រីក្រប្រើប្រាស់ធនធានវារីជាតនៅប្រទេសកម្ពុជា ដោយផ្តោតជាសំខាន់លើអ្នកនេសាទក្រីក្រនៅក្នុងខេត្តទាំង៣។

## ៤.៣.៣ រួមវិភាគទានដល់ភាពច្បាស់លាស់នៃនិយមន័យទាក់ទងទៅនឹងច្បាប់ជលផលថ្មី

តាមរយៈសិក្ខាសាលា និង វេទិកាពិភាក្សា STREAM មានផែនការប្រមូលយកនូវបទពិសោធន៍ទាំងឡាយទាក់ទងនឹង "នេសាទគ្រួសារ " និង និយមន័យផ្សេងៗទៀតដើម្បីជួយបំភ្លឺដល់មូលដ្ឋានច្បាប់សំរាប់សហគមន៍នេសាទ និង សហគ្រប់គ្រង។ ជាពិសេសទាក់ទងទៅនឹងអាណត្តិរបស់ STREAM ដូចជា ទំនាក់ទំនង ធ្វើការជាមួយ និង កសាងភាពជាដៃគូរ និង មានឥទ្ធិពលលើដំណើរការអភិវឌ្ឍន៍គោលនយោបាយ។

## ៤.៣.៤ ជាប់ទាក់ទងនឹងដំណើរការតាក់តែងច្បាប់

ដូចដែលបាននិយាយនៅត្រង់កន្លែងណាមួយនៃឯកសារនេះ ការប្រឈមមុខសំខាន់នៅកម្ពុជាគឺគោលនយោបាយវិស័យជលផលសព្វថ្ងៃ និង មាត្រាទី១៥នៃពង្រាងច្បាប់ថ្មី។ ឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង លោកប្រធាននាយកដ្ឋានជលផលបានសង្កត់ធ្ងន់ថា មាត្រាទី១៥ ចាំបាច់ត្រូវធ្វើការកែប្រែឡើងវិញដើម្បីឆ្លើយតបនឹងយុទ្ធសាស្រ្តចិញ្ចឹមជីវិតរបស់ "អ្នកនេសាទគ្រួសារ "កាន់តែប្រសើរឡើង និង ជួយដល់ការអភិវឌ្ឍន៍ជនបទឱ្យមាននិរន្តរភាព។ អ្នកទាំងពីរបានបញ្ជាក់សាជាថ្មីដល់ STREAM និង អ្នកឯទៀតថាការកសាងសមត្ថភាពលើការវិភាគការចិញ្ចឹមជីវិតគឺជាអាទិភាព និង បញ្ជាក់គំនិតចង់ប្រើប្រាស់នូវពត៌មានដែលទទួលបានមកពីការវិភាគបែបនេះដើម្បីបញ្ជាក់ទៅការកែប្រែលើមាត្រាទី១៥។ អ្នកទាំងពីរក៏បានស្នើឱ្យជួយផ្តល់នូវបទពិសោធន៍ពីគោលនយោបាយគ្រប់គ្រងសហគមន៍ និង ការអនុវត្តន៍នៅតំបន់ផ្សេងៗទៀតនៃអាស៊ីដោយសង្កត់ធ្ងន់ពីបទពិសោធន៍របស់ DFID នៅបង់ក្លាដែស និង ឱកាសសំរាប់រៀនសូត្រតាមរយៈបណ្តាញទំនាក់ទំនងរបស់ STREAM នៅក្នុងតំបន់។

ថ្វីត្បិតតែការជាប់ទាក់ទងជាមួយដំណើរការធ្វើគោលនយោបាយគឺមានភាពសាំញ៉ាំ និង មិនអាចកំនត់មុនបាន STREAM ប្តេជ្ញាជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំច្បាប់ជលផលថ្មី។ ដំណើរការនេះអាចជាការបន្តចរចា វាមានន័យថាវាជាការពិបាកចំពោះ STREAM ឱ្យដឹងពិតប្រាកដថាតើអាចជួយអ្វីបានខ្លះ ហើយមានករណីជាច្រើនគឺផ្អែកទៅលើឱកាស។ ក្នុងន័យនេះ ការត្រួតពិនិត្យនូវដំណើរការដែល STREAMបានកំនត់ និង ឆ្លើយតបទៅនឹងឱកាសដែលមានដើម្បីធ្វើការជាប់ទាក់ទងនឹងក្លាយទៅជាចំណុចសំខាន់មួយក្នុងការអនុវត្តន៍ CSP នេះ ។

## ៤.៤ ការទំនាក់ទំនង

ក្នុងកំឡុងពេលយូរ ការជួយដល់តំរូវការរបស់អ្នកក្រីក្រប្រើប្រាស់ធនធានវារីជាតនៅកម្ពុជាចាំបាច់ត្រូវលើកកំពស់លំហូរពត៌មានក្នុងចំណោម និង រវាងអ្នកក្រីក្រប្រើប្រាស់ធនធានវារីជាត អ្នកផ្តល់សេវាកម្ម អ្នកធ្វើគោលនយោបាយ និង ជួយស្ថាប័ន។ យើងត្រូវប្រកាន់ជំហរដោយធានាថាប្រព័ន្ធ និង រចនាសម្ព័ន្ធមាននៅនឹងកន្លែងដែលសំរួលដល់ការរៀន និង ចែករំលែកបទពិសោធន៍ និង ធនធានរវាងអ្នកជាប់ពាក់ព័ន្ធ។ នៅពេលនោះការយល់ដឹង និង ការទទួលស្គាល់បញ្ហានឹងកើនឡើង។ បញ្ហានេះវាអាចធ្វើបាននៅកម្ពុជាសព្វថ្ងៃដោយសារមានការជួយឧបត្ថម្ភពីអ្នកផ្តល់ជំនួយដល់ផ្នែកសហគមន៏នេសាទ។

តាមរយៈការអភិវឌ្ឍន៏ និង ទំនាក់ទំនងនៃមណ្ឌលទំនាក់ទំនងនៅកម្ពុជា ក៏ដូចជាមណ្ឌលទំនាក់ទំនងផ្សេងទៀតនៅបណ្តាប្រទេសអាស៊ីប៉ាស៊ីភិច STREAM នឹងសំរបសំរួលការចែករំលែកបទពិសោធនៃបណ្តាប្រទេសផ្សេងៗ (អំពីបច្ចេកទេស របៀបធ្វើការ របៀបលើកទឹកចិត្ត ទំរង់ច្បាប់ ការគ្រប់គ្រងនៅក្នុងបរិស្ថានណាមួយ របៀបធ្វើការត្រួតពិនិត្យ និង វាយតំលៃ) តាមរយៈទំនាក់ទំនងក្នុងចំណោមសមភាគីនៅបណ្តាប្រទេសផ្សេងៗ។ តាមរយៈការអភិវឌ្ឍន៏ភាពជាដៃគូរសមស្រប STREAM មានបំណងបង្កើនបណ្តាញអ្នកជាប់ពាក់ព័ន្ធ នៅថ្នាក់ជាតិ និង ភ្ជាប់ទំនាក់ទំនងបណ្តាញថ្នាក់ជាតិជាមួយតំបន់ទាំងមូល។

បន្ថែមលើទំនាក់ទំនងជាមួយបណ្តាញថ្នាក់ជាតិ និង សមភាគីដ៏ទៃទៀត STREAM នឹងសំរួលឱ្យទទួលបាននូវពត៌មានអន្តរជាតិ និង វិទ្យាសាស្ត្រតាមរយៈ Website។ ការងារនេះរួមមាន ការពិនិត្យលើបណ្តាញពត៌មាន ស្រាវជ្រាវ និង ភ្ជាប់ទំនាក់ទំនងជាមួយស្ថាប័នស្រាវជ្រាវ និង ស្រាវជ្រាវរក Website ដែលមានពត៌មានល្អៗ។ តួនាទីរបស់អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងគឺ បកប្រែ និង ចែករំលែកចំណេះដឹងសំខាន់ៗពីប្រភពផ្សេងៗទាំងនេះ។ ដើម្បីអភិវឌ្ឍន៏បណ្តាញជាតិសមស្របបំផុត ការទទួលបាននូវពត៌មានរបស់ប្រជាជន និង របៀបដែលគេជ្រើសរើសដើម្បីចែករំលែកពត៌មានទាំងនេះនឹងត្រូវបានគេធ្វើអង្កេតនៅកម្ពុជា។ មធ្យោបាយពីរសំរាប់ការទំនាក់ទំនងនៅក្នុងតំបន់គឺ ទស្សនាវដ្តីប្រចាំត្រីមាសរបស់ STREAM និង ពត៌មានថ្មីពី STREAM ដែលត្រូវបានបោះពុម្ភ និង ចែកចាយដោយមណ្ឌលទំនាក់ទំនងនៅកម្ពុជាជាភាសាខ្មែរ និង ភាសាអង់គ្លេស។

មធ្យោបាយទំនាក់ទំនងជាច្រើនទៀតទាត់មួយទៀតត្រូវបានអភិវឌ្ឍន៏ និង រក្សាទុកដើម្បីភ្ជាប់ទំនាក់ទំនងដៃគូរកម្ពុជាជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់អាស៊ីប៉ាស៊ីភិច ដែលក្នុងនោះរួមមានៈ កិច្ចប្រជុំតាមរយៈអ៊ីមែលរៀងរាល់២សប្តាហ៏ សន្និសីទថ្នាក់តំបន់ប្រចាំឆ្នាំ សិក្ខាសាលា និង កិច្ចប្រជុំ។

## ៥. ភាពជាដៃគូរ

គំរោង STREAM ត្រូវបានបង្កើតឡើង និង អភិវឌ្ឍន៍ដោយក្រុមដៃគូរដែលជាប់ទាក់ទិននឹងការជួយឧបត្ថម្ភការគ្រប់គ្រងធនធានវារីជាតនៅក្នុងតំបន់ និង មានការចាប់អារម្មណ៏ដល់ការចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ។ ក្នុងកិច្ចខិតខំប្រឹងប្រែងនេះរដ្ឋាភិបាលជាសមាជិករបស់ NACA ដោយសហការជាមួយនាយកដ្ឋានដើម្បីអភិវឌ្ឍន៏របស់ចក្រភពអង់គ្លេស (DFID)-កម្មវិធីគ្រប់គ្រងធនធានវារីជាត (ARMP) អង្គការស្បៀង និង កសិកម្មពិភពលោក (FAO) នាយកដ្ឋានវារីវប្បកម្មនៅទីក្រុងរ៉ូម និង ការិយាល័យថ្នាក់តំបន់ (អាស៊ី និង ប៉ាស៊ីភិច) នៅទីក្រុងបាងកក និង អង្គការអន្តរជាតិ (VSO)។

បន្ទាប់ពីមានសំណើទៅក្រុមប្រឹក្សាដឹកនាំរបស់ NACA កិច្ចព្រមព្រៀងដើម្បីអនុវត្តគំរោង STREAM នៅកម្ពុជាត្រូវបានចុះហត្ថលេខារវាងការិយាល័យអភិវឌ្ឍន៏សហគមន៏នេសាទនៃនាយកដ្ឋានជលផលភ្នំពេញ កម្មវិធី SCALE និង គំរោង STREAM នៅថ្ងៃទី២ ខែ វិច្ឆិកា ឆ្នាំ ២០០១។

នៅថ្នាក់ខេត្ត ភាពជាដៃគូរត្រូវបានអភិវឌ្ឍន៏តាមរយៈការកសាងសមត្ថភាពលើការវិភាគការចិញ្ចឹមជីវិត ដោយរួមបញ្ចូលកម្មវិធី SCALE ការិយាល័យជលផល និង មន្ទីរកិច្ចការនារីខេត្ត កំពង់ឆ្នាំង កណ្តាល និង ក្រចេះ។

នៅពេលដែល STREAM អភិវឌ្ឍន៏នៅកម្ពុជា និង នៅក្នុងតំបន់ គេបានស្នើឱ្យអភិវឌ្ឍន៏ដៃគូរបន្ថែមទៀតជាមួយនឹងអ្នកផ្តល់ជំនួយ អ្នកអនុវត្ត និង អ្នកដែលបង្កើត និង ចែករំលែកចំណេះដឹងដើម្បីជួយដល់ការរៀនសូត្រ និង ទំនាក់ទំនងក្នុងចំណោមអ្នកជាប់ពាក់ព័ន្ធក៏ដូចជាមួយស្ថាប័នស្រាវជ្រាវ និង អភិវឌ្ឍន៏ អន្តរជាតិ និង តំបន់។

## ៦. ធនធាន

ជាគំរោង (Initiative) ថ្នាក់តំបន់ STREAM គ្មានធនធានគ្រប់គ្រាន់ដើម្បីផ្តល់មូលនិធិទាំងស្រុងដើម្បីអនុវត្តអត្ថបទយុទ្ធសាស្រ្តរបស់ប្រទេសនោះទេ។ ថ្វីត្បិតតែ STREAM អាចផ្តល់មូលនិធិ "ចាប់ផ្តើម "សំរាប់ការអនុវត្តន៏យុទ្ធសាស្រ្តដែលបានចែងនៅក្នុងឯកសារនេះ ការរួមវិភាគទានគឺមានកំរិតតិចតួច ប្រហែលតិចជាង២០%នៃមូលនិធិសរុបដែលត្រូវការ។ ធានានូវធនធានដើម្បីសំរេចនូវទិសដៅដាក់ចេញនៅក្នុងអត្ថបទយុទ្ធសាស្រ្តនេះគឺជាអាណត្តិរបស់ STREAM នៅកម្ពុជា។ គេទទួលស្គាល់ថាការធានានូវមូលនិធិទាំងនេះគឺជាការលំបាក។ វាទាមទារឱ្យមានការទទួលខុសត្រូវ និង ផ្តល់ឱកាសឱ្យSTREAMកម្ពុជា ការិយាល័យ STREAM ថ្នាក់តំបន់ និង ដៃគូរ STREAMទាំងអស់ ធ្វើការរួមគ្នាដើម្បីស្វែងរក និង តាមដានអ្នកផ្តល់មូលនិធិសំខាន់ៗ។

មានការរីកចំរើនខ្លះៗរួចទៅហើយដូចជា រកឃើញនូវសក្តានុពលប្រភពមូលនិធិពីផ្នែក ទ្វេភាគី ពហុភាគី មិនមែនរដ្ឋាភិបាល នៅកម្ពុជា អាស៊ីអគ្នេយ៏ អ៊ឺរ៉ុប និង អាមេរិកខាងជើង។ ការធ្វើផែនការតាមដានសកម្មភាពដើម្បីកំនត់ពីរបៀប STREAM និងដៃគូរ អាចសំរបសំរួលកិច្ចខិតខំរបស់ខ្លួន និង ប្រាក់ចំណូលច្រើនពីប្រភពមូលនិធិទាំងនេះគឺជាសកម្មភាពអាទិភាព។ ជាមួយគ្នានេះ ការរួមវិភាគទានជាប្រាក់ និង ប្រាក់បដិភាគត្រូវបាន និង នឹងបន្តធ្វើដល់ STREAM កម្ពុជាពីប្រភពជាច្រើន រួមទាំងរដ្ឋាភិបាល (នាយកដ្ឋានជលផល) កម្មវិធី STREAM ដៃគូរផ្តល់ជំនួយរបស់ STREAM ( DFID, AusAID, FAO និង VSO)និង បណ្តារដ្ឋាភិបាលនៅតំបន់អាស៊ីប៉ាស៊ីភិច (តាមរយៈ NACA)។

ក្នុងករណីខ្លះ វាជាការសំខាន់ដែលត្រូវទទួលស្គាល់ថា មធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតដើម្បីទទួលបាននូវឥទ្ធិពលគឺ STREAMត្រូវមានឥទ្ធិពលលើវិធីដែលអ្នកជាប់ពាក់ព័ន្ធទាំងអស់ប្រើប្រាស់ធនធានរបស់ខ្លួនចៀសជាងផ្តល់មូលនិធិឱ្យដោយផ្ទាល់។ វាសមស្របនៅក្នុងស្ថានភាពរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដោយមានអ្នកផ្តល់ជំនួយកាន់តែច្រើនជួយដល់សកម្មភាពទាក់ទងនឹងសហគមន៍នេសាទ។ ដូច្នេះ យុទ្ធសាស្រ្តសំខាន់របស់ STREAM ក្នុងការស្វែងរកធនធានគឺរកមធ្យោបាយដែលអាចធ្វើការជាមួយនឹងអ្នកជាប់ពាក់ព័ន្ធផ្សេងៗទៀតដើម្បីធានាធនធានដែលមានត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពក្នុងការដោះស្រាយនូវបញ្ហាសំខាន់ៗ និង ការលំបាកដែលបានរកឃើញនៅក្នុងឯកសារនេះ។

# ៧. ឯកសារយោង

Ahmed et al. 1998 Socio-economic assessment of freshwater capture fisheries of Cambodia, Report on a household survey, MRC/DANIDA/DoF. Management of Freshwater Capture Fisheries of Cambodia.

Azimi et al. 2000 Environments in transition: Cambodia, Lao PDR, Thailand, Vietnam. Asian Development Bank.

*Cambodia Daily* Newspaper 2000 Between home and hope, land grab squatters stranded with little resolution (April 29-30). Expert says dispute calls for fishing reform (May 25). Weak policy blamed for fisheries conflict (September 1).

Degen et al. 2000 Taken for granted: Conflicts over Cambodia's freshwater fish resources. Paper written for the 8th IASCP Conference, Bloomingdale, Indiana.

EWG 2000 Review of fisheries conflict in Stung Treng. Environment Working Group, NGO Forum.

FPO 2000 A study on the downstream impacts of the Yali Falls Dam in the Sesan River basin in Ratanakiri Province, in co-operation with the Non-timber Forest Products Project, Ratanakiri Province.

Kato, E 1999 Where has all the fish gone? Land rights and access in Cambodia. Volume 1 Case Studies, Oxfam GB.

Oxfam 2000 Inland Aquatic Resources and Livelihoods in Cambodia. Consultancy Report. Oxfam GB.

Phiak 2000 Draft report of workshop on the downstream impacts of the Yali Falls Dam in the Sesan River basin in Ratanakiri Province.

Sithirith, M 2000 Fishing conflict in Battambang. NGO Forum.

Swift, P 1999 Long-term case study of the fishery setting in Phlong Village, Kampong Chhnang Province. Initial information gathering and outline for future work programme, Report on fieldwork carried out 7-16 June 1999.

Thuok, N and Song, S L 1999 Report on field survey work of fishing lot #6 Kampong Klenag Commune, Sotr Nikum District, Siem Reap Province. Cambodia DOF with support from GCP/CBM/002/BEL.

Van Acker, F 1999 Land tenure: Hitting a stone with an egg? *Cambodia Development Review 3*(3). Cambodia Development Resources Institute.